# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១- ព្រះរាជក្រម

### ព្រះរាជក្រម នស/រកម/១១៩៩/១២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១០ មាត្រា១១ មាត្រា១៥ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣

មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤០ មាត្រា៤២ មាត្រា៤៤ ក្នុងជំពូកទី២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី៤ និង មាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី១ ដែលមានសេចក្ដីទាំងស្រុងដូចតទៅ ៖

**ច្បាប់**

**ស្ដីពី**

**វិសោធនកម្មមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤០ មាត្រា៤២ មាត្រា៤៤ ក្នុងជំពូកទី២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី៤ និង មាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម**

**មាត្រាតែមួយ.-** មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤០ មាត្រា៤២ មាត្រា៤៤ ក្នុងជំពូកទី២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី៤ និងមាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ត្រូវកែប្រែដូចតទៅ ៖

**មាត្រា១០ថ្មី.-** ការគ្រប់គ្រងនិងកាន់កាប់នូវបញ្ជីអ្នកចុះអត្តលេខនៃពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្ម ដែលហៅថា «បញ្ជីពាណិជ្ជកម្ម» ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា១១ថ្មី.-** ក្រសួងពាណិជ្ជកម្មត្រូវបញ្ជូនច្បាប់ចំលងនៃសៀវភៅបញ្ជីពាណិជ្ជកម្ម និងរាល់ឯកសារដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្មនីមួយៗ ជូនទៅតុលាការពាណិជ្ជកម្ម ដើម្បីតំកល់ជាឯកសារសំរាប់យុត្តាធិការពាណិជ្ជកម្ម ។

**មាត្រា១៤ថ្មី.-** យ៉ាងតិចបំផុតដប់ប្រាំថ្ងៃ (១៥ថ្ងៃ) មុនពេលចាប់ផ្ដើមបើកធ្វើពាណិជ្ជកម្មរបស់ខ្លួន ពាណិជ្ជករត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនាកន្លែងដែលខ្លួនធ្វើអាជីវកម្ម ។

ទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មមាននៅតាមមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ឬនៅទីកន្លែងផ្សេងទៀត តាមការកំណត់របស់ក្រសួងពាណិជ្ជកម្ម ។

ពាណិជ្ជករត្រូវប្រគល់ទៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្ម នូវប្រតិវេទន៍មួយធ្វើជាពីរច្បាប់ មានចុះហត្ថលេខា ឬស្នាមមេដៃរបស់សាមីខ្លួន ។

ប្រតិវេទន៍នេះត្រូវសរសេរលើលិខិតគំរូមួយ ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មបានផ្តល់ឲ្យ ។ ប្រតិវេទន៍ត្រូវចែងអំពី :

១- នាមត្រកូល និងនាមខ្លួនរបស់ពាណិជ្ជករ និងលេខ នៃលិខិតអត្តសញ្ញាណរបស់ខ្លួន ។

២- នាមប្រើប្រាស់ក្នុងពាណិជ្ជកម្ម ឬរហស្សនាម ។

៣- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ព្រមទាំងអាសយដ្ឋានផ្ទាល់ខ្លួន ។

៤- សញ្ជាតិដើម ហើយក្នុងករណីដែលសាមីខ្លួនបានទទួលសញ្ជាតិមួយផ្សេងទៀត ត្រូវបញ្ជាក់អំពីរបៀបទ និងថ្ងៃ ខែ ឆ្នាំ ដែលបានទទួលសញ្ជាតិនេះ ។

៥- កម្មវត្ថុពាណិជ្ជកម្ម ។

៦- ទីកន្លែងធ្វើអាជីវកម្ម និងអាសយដ្ឋានគ្រឹះស្ថាន ឬសាខានៃមូលនិធិពាណិជ្ជកម្ម ដែលមានទីតាំងនៅព្រះរាជាណាចក្រកម្ពុជា

៧- ផ្លាកសញ្ញាពាណិជ្ជកម្មនៃគ្រឹះស្ថាន និងហត្ថលេខាគំរូរបស់សាមីខ្លួន ព្រមទាំងស្នាមត្រាគំរូ ។

៨- លិខិតអត្តសញ្ញាណរបស់អ្នកតំណាងពេញសិទ្ធិ ដែលទទួលការងារក្នុងការសុំចុះ បញ្ជីពាណិជ្ជកម្ម ។

៩- គ្រឹះស្ថានពាណិជ្ជកម្មដែលអ្នកស្នើសុំបានធ្វើអាជីវកម្មពីមុន ឬគ្រឹះស្ថានពាណិជ្ជកម្មដែលអ្នកស្នើសុំកំពុងធ្វើអាជីវកម្មនៅក្នុងរង្វង់សមត្ថកិច្ច ក្រសួងពាណិជ្ជកម្ម ។

១០- សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថា គ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម ។

១១- ក្នុងករណីចាំបាច់ លិខិតអនុញ្ញាតឲ្យប្រកបមុខរបរ ចំពោះមុខរបរណា ឬចំពោះកម្មវត្ថុពាណិជ្ជកម្មណាដែលតម្រូវឲ្យមានសេចក្តីអនុញ្ញាត ។ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវចម្លងសេចក្តីក្នុងប្រតិវេទន៍ចូលក្នុងបញ្ជីពាណិជ្ជកម្ម ដោយប្រគល់ប្រតិវេទន៍នេះ មួយច្បាប់ក្នុងចំណោមប្រតិវេទន៍ទាំងពីរច្បាប់ ជូនទៅអ្នកស្នើសុំចុះឈ្មោះដោយបញ្ជាក់នៅខាងក្រោមថា "បានចម្លងចូលបញ្ជីរួចហើយ" ។

**មាត្រា១៦ថ្មី .-** ការចុះនិទ្ទេសដូចមានចែងក្នុងមាត្រា១៥ នៃច្បាប់នេះ ជាភារកិច្ចផ្ទាល់ខ្លួនរបស់ពាណិជ្ជករ ។ ប៉ុន្តែចំពោះករណីដែលមានចែងនៅក្នុងចំណុច ២, ៤និង ៦

នៃមាត្រា១៥ មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្មអាចចុះសេចក្តីនោះជាបញ្ញត្តិក្នុងបញ្ជីពាណិជ្ជកម្ម ដែលសាមីពាណិជ្ជករបានចុះឈ្មោះ ។

**មាត្រា១៧ថ្មី .-** គ្រប់ក្រុមហ៊ុន ដែលមានសកម្មភាពពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្ម ទោះបីកន្លែងនៃការបង្កើតនិងទីស្នាក់ការរបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ ។

ការចុះឈ្មោះនេះ ត្រូវធ្វើឡើងដោយបណ្ណាធិការ ឬអភិបាលនៃសាមីក្រុមហ៊ុន នៅក្នុងខែនៃការបង្កើតក្រុមហ៊ុន និងដប់ប្រាំថ្ងៃ (១៥ថ្ងៃ) មុនកាលបរិច្ឆេទបើកប្រតិបត្តិការពាណិជ្ជកម្ម ។

អ្នកស្នើសុំចុះឈ្មោះ ត្រូវផ្តល់ដល់ទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនូវប្រតិវេទន៍ចំនួនពីរច្បាប់ មានចុះហត្ថលេខារបស់សាមីខ្លួនអ្នកស្នើសុំព្រមទាំងតំកល់លក្ខន្តិកៈក្រុមហ៊ុនផង ។

ប្រតិវេទន៍ ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មផ្តល់គំរូជូននោះត្រូវចែងអំពី :

១- នាមត្រកូលនិងនាមខ្លួន រហស្សនាមរបស់សមាជិកក្រុមហ៊ុន ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ស្ថានភាពគ្រួសារ និងសញ្ជាតិ ។

២- ផ្លាកសញ្ញារបស់ក្រុមហ៊ុន ។

៣- កម្មវត្ថុនៃក្រុមហ៊ុន ។

៤- ទីកន្លែងទាំងឡាយដែលក្រុមហ៊ុនមានគ្រឹះស្ថានដើមមានសាខា ឬទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា ។

៥- នាមនៃសមាជិកឬតតិយជនដែលមានការអនុញ្ញាតឲ្យគ្រប់គ្រង ចាត់ចែង ចុះចាត់ចែង និងចុះហត្ថលេខាជំនួសមុខក្រុមហ៊ុន ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតនៃអ្នកទាំងនេះ ។

៦- ដើមទុនរបស់ក្រុមហ៊ុន ប្រភពដើមទុន និងចំនួនទឹកប្រាក់ ឬវត្ថុមានតំលៃដែលផ្តល់ដោយសមាជិកភាគហ៊ុន ប្រសិនបើជាក្រុមហ៊ុនដោយភាគហ៊ុន ។

៧- ថ្ងៃ ខែ ឆ្នាំ ដែលក្រុមហ៊ុននោះចាប់ផ្តើម និងបញ្ចប់ ។

៨- ទ្រង់ទ្រាយក្រុមហ៊ុន ។

៩- ហត្ថលេខាគំរូរបស់សមាជិក ឬតតិយជនដូចមានចែងនៅចំណុចលេខ៥ នៃមាត្រានេះ និងស្នាមត្រាគំរូរបស់ក្រុមហ៊ុន ។

១០- លិខិតបញ្ជាក់អំពីការតម្កល់ដើមទុនចេញដោយធនាគារ ។

១១- សេចក្តីប្រកាសដោយកេរ្តិ៍សក្តិរបស់អ្នកស្នើសុំថា គ្មានជាប់ទោសពាក់ព័ន្ធក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណីឬព្រហ្មទណ្ឌ ។

**មាត្រា២១ថ្មី .-** ប្រតិវេទន៍ធ្វើឡើងជាពីរច្បាប់ត្រូវយកទៅដាក់ដោយអ្នកស្នើសុំ ឬដោយអាណត្តិគាហក របស់សាមីជននោះ ។ ក្នុងករណីនេះ អាណត្តិគាហកត្រូវមានលិខិតប្រគល់សិទ្ធិអំណាច ដែលត្រូវតម្កល់ទុកនៅការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

**មាត្រា២២ថ្មី .-** បើប្រតិវេទន៍ត្រូវបានយកទៅដាក់ផ្ទាល់ដោយអ្នកស្នើសុំនោះ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវពិនិត្យផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់សាមីខ្លួនឲ្យបានត្រឹមត្រូវ ។ បើសិនប្រតិវេទន៍នេះ ត្រូវបានយកទៅតម្កល់ទុកដោយអាណត្តិគាហក មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវតម្រូវឲ្យមានការបញ្ជាក់អំពីហត្ថលេខារបស់អាណត្តិទាយក ឬការបញ្ជាក់អំពីស្នាមមេដៃ បើអាណត្តិទាយកមិនចេះចុះហត្ថលេខា និងតម្រូវឲ្យបង្ហាញលិខិតបញ្ជាក់អត្តសញ្ញាណ របស់អ្នកស្នើសុំ ។

**មាត្រា២៥ថ្មី .-** មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនឹងផ្ទៀងផ្ទាត់មើលក្រោមការទទួលខុសត្រូវផ្ទាល់ របស់ខ្លួនអំពីឯកសារទាំងឡាយដែលបានបញ្ជាក់ ។ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវចុះនៅលើផ្នែកខាងលើនៃប្រតិវេទន៍នូវ ៖

១- ថ្ងៃ ខែ ឆ្នាំ ម៉ោងនៃការតម្កល់ទុក និងទីកន្លែងក្រសួងពាណិជ្ជកម្ម ។

២- លេខរៀងរបស់ប្រតិវេទន៍តាមលំដាប់លេខជាបន្តបន្ទាប់ ក៏ប៉ុន្តែការចុះលេខនេះ ត្រូវចាប់ផ្តើមឡើងវិញចាប់ពីថ្ងៃទី ០១ មករា ជារៀងរាល់ឆ្នាំ ។

៣- អត្តលេខសំគាល់ទៅតាមប្រភេទនៃសកម្មភាពរបស់ពាណិជ្ជករ ដែលចុះក្នុងបញ្ជីភាគដែលនឹងមានចែងខាងក្រោយ ។

ចំពោះអ្នកធ្វើប្រតិវេទន៍ណាដែលមិនបានផ្តល់នូវព័ត៌មានគ្រប់គ្រាន់ ដល់ការចុះបញ្ជី នឹងត្រូវបានអនុញ្ញាតរយៈពេលពិសេសចំនួនដប់ប្រាំថ្ងៃ (១៥ថ្ងៃ)បន្ថែម ។

**មាត្រា២៦ថ្មី .-** ដោយបានឃើញប្រតិវេទន៍ជាលាយលក្ខណ៍អក្សរ និងរាល់ឯកសារតម្កល់ តម្កល់ទុក មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនឹងផ្តល់នូវវិញ្ញាបនបត្រចុះបញ្ជីហៅថា "សរវ៉េ" ដែលមានចែងអត្តលេខសំគាល់ចុះក្នុងបញ្ជីពាណិជ្ជកម្ម ។ វិញ្ញាបនបត្រនេះ ស្ថិតក្នុងលក្ខណៈបណ្តោះអាសន្នក្នុងថិរវេលាមួយខែ (១ខែ) គិតចាប់ពីកាលបរិច្ឆេទ ដែលបានផ្តល់ជូន ។ ក្នុងថិរវេលានេះ ប្រសិនបើរកឃើញថាជាប្រតិវេទន៍ក្លែងបន្លំ មន្ត្រីចុះបញ្ជី

ពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម អាចជំទាស់នឹងការចុះបញ្ជីនិងតុបតែងលេខ សំគាល់ ដែលមានចុះក្នុងបញ្ជីហើយនោះ ។

មន្ត្រីចុះបញ្ជីពាណិជ្ជកម្មដែលផ្តល់នូវវិញ្ញាបនប័ត្រក្លែងបន្លំ ដែលបានធ្វើឡើង ដោយដឹងហេតុផលសព្វគ្រប់ ត្រូវទទួលទោសតាមច្បាប់ ។

មាត្រា២៨ថ្មី .- កាលណាបើពាណិជ្ជករណាម្នាក់ឈប់ប្រកបពាណិជ្ជកម្មរបស់ខ្លួន ឬទទួល មរណភាព ដោយពុំបានធ្វើអនុប្បទានទ្រព្យនូវមូលនិធិពាណិជ្ជកម្មរបស់ខ្លួន ឬកាលណាបើក្រុមហ៊ុន ណាមួយត្រូវរំលាយនោះ ត្រូវលុបឈ្មោះពាណិជ្ជករនោះ ឬក្រុមហ៊ុននោះចេញពី បញ្ជី។

បើសិនជាគ្មានការសុំលុបឈ្មោះដោយពាណិជ្ជករឬដោយអ្នកទទួលមរតក ឬ ដោយអ្នកជំរះបញ្ជី ការលុបឈ្មោះចេញពីបញ្ជីនេះត្រូវធ្វើឡើងដោយបញ្ញត្តិតាម សេចក្តីសំរេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

រាល់ឯកសារដែលពាក់ព័ន្ធនឹងការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មនេះ ត្រូវ ចំលងជូនទៅតុលាការពាណិជ្ជកម្ម ដើម្បីតំកល់ជាឯកសារសំរាប់យុត្តាធិការពាណិជ្ជកម្ម។

មាត្រា២៩ថ្មី .- ជនណាក៏ដោយអាចសុំឲ្យមន្ត្រីចុះបញ្ជីពាណិជ្ជកម្មចេញឲ្យខ្លួននូវវិញ្ញាបនប័ត្រ បញ្ជាក់ អំពីចំណារទាំងឡាយ ដែលមានចុះក្នុងបញ្ជីពាណិជ្ជកម្ម ។ បើគ្មានចុះបញ្ជីទេ មន្ត្រី ចុះបញ្ជីពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនប័ត្របញ្ជាក់ថា គ្មានចុះបញ្ជី ។

ការធ្វេសប្រហែស ឬការមិនព្រមចេញវិញ្ញាបនប័ត្រក្នុងរយៈពេលមួយសប្តាហ៍ គិតចាប់ពីថ្ងៃស្នើសុំ នឹងបណ្តាលឲ្យមានទណ្ឌកម្មតាមវិន័យចំពោះមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ព្រមទាំងមានការសងជំងឺចិត្តផង ។

សេចក្តីចំឡង ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មចេញឲ្យនោះ មិនត្រូវចែងសាល ក្រមប្រកាសធនក្ស័យឬការជំរះបញ្ជីតាមផ្លូវតុលាការទេ បើក្រោយមកមាននីតិសម្បទា ឡើងវិញ ។ សេចក្តីចំឡងក៏មិនត្រូវចុះផងដែរនូវសាលក្រម ឬសាលដីកាហាមឃាត់ មិនឲ្យធ្វើពាណិជ្ជកម្ម ឬសាលក្រម សាលដីកាតែងតាំងក្រុមប្រឹក្សាជំនួយ បើមាន លើកការហាមឃាត់ចេញរួចហើយ ។

មាត្រា៣០ថ្មី .- បញ្ជីពាណិជ្ជកម្ម ដែលតំកល់ទុកនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួង ពាណិជ្ជកម្ម មានពីរបែប គឺ :

១- បញ្ជីកាលប្បវត្តិ

២- បញ្ជីវិភាគ

មាត្រា៣១ថ្មី .- ប្រតិវេទន៍ត្រូវចុះក្នុងបញ្ជីកាលប្បវត្តិ តាមលំដាប់នៃការតំកល់ទុកនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្ម និងតាមលេខដែលចុះ ។

ត្រូវប្រគល់ចុងសន្លឹកនៃប្រតិវេទន៍មួយសន្លឹក ដែលដាច់ចេញពីគល់បញ្ជីហៅថា "គល់រង់" ជាសំគាល់នៃការតំកល់ទុកដោយមានចែងនិទ្ទេសដូចតទៅ :

១- លេខរៀងនៃប្រតិវេទន៍

២- ថ្ងៃ ខែ ឆ្នាំ ម៉ោងនៃការតំកល់ទុក និងទីកន្លែងនៃក្រសួងពាណិជ្ជកម្ម

៣- នាមត្រកូល នាមខ្លួន ផ្លាកសញ្ញាក្រុមហ៊ុន និងលំនៅដ្ឋានអ្នកធ្វើប្រតិវេទន៍ ។

ចំណែកឯបញ្ជីវិភាគវិញ មានទ្រង់ទ្រាយជាតារាងដែលត្រូវចុះជាអាទិ៍នូវលេខថ្ងៃ ខែ ឆ្នាំ ម៉ោងនៃការតំកល់ទុក អត្តលេខ នាមករណ៍ក្រុមហ៊ុន កម្មវត្ថុនៃក្រុមហ៊ុន ដើមទុននៃក្រុមហ៊ុន ។ គ្រឹះស្ថានពាណិជ្ជកម្មនីមួយៗដែលជាកម្មវត្ថុនៃការចុះអត្តលេខសំគាល់ដោយឡែក ត្រូវបានចុះលើសន្លឹកមួយទាំងសងខាង ហើយនៅលើសន្លឹកនោះ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវចារលេខប្រតិវេទន៍ដើមនៃការសុំចុះបញ្ជីនោះ ។

មាត្រា៣២ថ្មី .- បើមានពាក្យសុំឲ្យចុះនិទ្ទេសដែលបង្កឲ្យលុបចោលនិទ្ទេសដែលមានស្រាប់ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវគូសលុបនិទ្ទេសនេះ ដោយទឹកខ្មៅក្រហម ឬលុបខ្វែងចំណាំតាមកម្មវិធីកុំព្យូទ័រ ដោយមានសរសេរបង្ហាញនៅរឹមទំព័រនូវសេចក្ដីយោងនៃនិទ្ទេសថ្មី និងលេខ ដែលក្រោមលេខនេះ ប្រតិវេទន៍ ឬពាក្យសុំចុះនិទ្ទេសនោះ ត្រូវបានចុះបញ្ជីដោយពិតប្រាកដ ។

មាត្រា៣៣ថ្មី .- បើសិនមានការលុបឈ្មោះចេញពីបញ្ជី ការលុបនេះត្រូវធ្វើឡើងដោយគំនូសក្រហមពីរខ្វែងគ្នា ឬលុបតាមវិធីកុំព្យូទ័រ ។

សេចក្ដីសំរេចលុបឈ្មោះចេញពីបញ្ជីដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬពាក្យសុំឲ្យលុបឈ្មោះនោះ ត្រូវកំណត់សំគាល់សរសេរនៅលើរឹមទំព័រដោយទឹកខ្មៅក្រហមផងដែរ ។

មន្ត្រីចុះបញ្ជីពាណិជ្ជកម្មបញ្ជាក់និទ្ទេសនេះ ដោយចុះហត្ថលេខាសង្ខេប ។

មាត្រា៣៤ថ្មី .- កាលបើនិទ្ទេសដែលមាននៅក្នុងប្រតិវេទន៍ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងបញ្ជី វិភាគ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវប្រគល់ជូនអ្នកដែលបានមកតំកល់ទុកនូវប្រតិវេទន៍ មួយច្បាប់ ដែលមានចុះហត្ថលេខាត្រឹមត្រូវសំរាប់ប្រើប្រាស់ជាវិញ្ញាបនប័ត្រចុះឈ្មោះ ។

សន្លឹកប្រតិវេទន៍ទាំងអស់ ដែលរក្សាទុកនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ត្រូវមន្ត្រីចុះបញ្ជីពាណិជ្ជកម្មចងក្រងតាមលេខរៀងយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ ។

**មាត្រា៣៥ថ្មី .-** បញ្ជីកាលប្បវត្តិ និងបញ្ជីវិភាគត្រូវបានរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាអ្នកបង់លេខ ចុះហត្ថលេខាសង្ខេប និងពិនិត្យបញ្ជាក់នៅពេលដាច់ខែម្តងៗ ។ ការពិនិត្យ បញ្ជាក់នេះ ត្រូវមានបោះត្រារបស់ក្រសួងពាណិជ្ជកម្ម និងចុះហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

បើរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបញ្ជាក់ថាប្រតិវេទន៍លោកម្ចាស់ក្នុងការលើកលែង មានចែងក្នុងមាត្រា៤០ថ្មី និងមាត្រា៤១ នៃច្បាប់នេះ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវប្តឹងអំពីរឿងនេះ ទៅព្រះរាជអាជ្ញាអមតុលាការ មានសមត្ថកិច្ច ។

**មាត្រា៣៦ថ្មី .-** ការចុះឈ្មោះ ការលុបឈ្មោះ ឬការចេញវិញ្ញាបនប័ត្រផ្សេងៗជាភារៈផ្ទាល់របស់មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ។ វិញ្ញាបនប័ត្រទាំងនេះ ត្រូវចេញឲ្យអ្នកស្នើសុំតាមក្បាលបញ្ជីមានលេខ ។ អាករលើបែបបទស្នើសុំចុះឈ្មោះ លុបឈ្មោះ ឬចេញវិញ្ញាបនប័ត្រផ្សេងៗ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយប្រមូលដោយមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម សំរាប់បង់ចូលថវិកាជាតិ ។

**មាត្រា៣៧ថ្មី .-** សេចក្តីចំលងនៃការចុះឈ្មោះក្នុងបញ្ជី ការលុបឈ្មោះចេញពីបញ្ជី និងវិញ្ញាបនប័ត្របញ្ជាក់ពីការគ្មានចុះឈ្មោះចេញដោយមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ត្រូវផ្តល់ជូនដោយឥតគិតថ្លៃតាមពាក្យសុំរបស់អាជ្ញាធរតុលាការ ឬរដ្ឋបាលបោន ប៉ុន្តែត្រូវតែមានចុះនិទ្ទេសពីកន្លែងអ្នកទទួលលិខិតនោះ ។

**មាត្រា៣៨ថ្មី .-** រាល់ការចុះឈ្មោះក្នុងបញ្ជី និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ត្រូវបានចុះផ្សាយដោយមន្ត្រីចុះបញ្ជីពាណិជ្ជកម្មក្នុងរាជកិច្ច ។ និទ្ទេសដែលត្រូវចុះផ្សាយមានដូចខាងក្រោមនេះ :

ក-ចំពោះពាណិជ្ជករ

១- លេខចុះបញ្ជី
២- នាមត្រកូល នាមខ្លួន រហស្សនាម ព្រមទាំងនាមសព្វនាម
៣- សកម្មភាព ទីកន្លែង ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើមសកម្មភាព
៤- ផ្លាកសញ្ញា ។

ខ-ចំពោះក្រុមហ៊ុន

១- លេខចុះបញ្ជី
២- នាមករណ៍
៣- ចំនួនដើមទុន
៤- ទីស្នាក់ការ
៥- សកម្មភាព និងថ្ងៃ ខែ ឆ្នាំចាប់ផ្តើម
៦- ទ្រង់ទ្រាយក្រុមហ៊ុន ។

**មាត្រា៤០ថ្មី.-** ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី (ប្រាំម៉ឺន) ៥០.០០០រៀល ទៅ(ប្រាំសែន) ៥០០.០០០រ ចំពោះ :

១- រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលមិនបានចុះបញ្ជីពាណិជ្ជកម្មតាមការកំណត់ ។

២- រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មហើយ តែមិនបានចុះនៅលើវិក្កយបត្រ លិខិតស្នាមកំណត់បញ្ជាទិញ តារាងតំលៃឯកសារផ្សព្វផ្សាយអំពីទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្ម ដែលខ្លួនបានចុះឈ្មោះនិងលេខដែលខ្លួនបានចុះក្នុងបញ្ជីពាណិជ្ជកម្ម ។

**មាត្រា៤២ថ្មី .-** រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលបានផ្តល់នូវព័ត៌មានមិនពិតដោយចេតនាទុច្ចរិត ដើម្បីនឹងសុំចុះលេខ ឬសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយឆ្នាំ (១ឆ្នាំ) ទៅប្រាំឆ្នាំ (៥ឆ្នាំ) និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី មួយលាន (១.០០០.០០០) រៀល ទៅដប់លាន (១០.០០០.០០០) រៀល ។

ក្នុងករណីដែលមានការផ្លាស់ប្តូរកែប្រែព័ត៌មានដូចបានកំណត់ក្នុងមាត្រា ១៥ ចំណុច១ មាត្រា១៨ ចំណុច១ និងមាត្រា២០ រាល់ពាណិជ្ជករ ឬអ្នកដឹកនាំក្រុមហ៊ុនណាដែលមិនបានបំពេញបែបបទនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ក្នុងរយះពេលដប់ប្រាំថ្ងៃ (១៥ថ្ងៃ) ក្រោយពីមានការផ្លាស់ប្តូរ កែប្រែនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីប្រាំសែន (៥០០.០០០) រៀល ទៅមួយលាន (១.០០០.០០០) រៀល ។

**មាត្រា៤៤ថ្មី .-** ក្នុងករណីមិនរាងចាល ការផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ៤០ថ្មី វាក្យខ័ណ្ឌទី១ នៃមាត្រា៤២ថ្មី មាត្រា៤៣ ត្រូវអនុវត្តកំរិតអតិបរមា ហើយបើមានបទល្មើស ដែលបានកំណត់ក្នុងវាក្យខ័ណ្ឌទី២ នៃមាត្រា ៤២ថ្មី មិនរាងចាលនោះ រាល់ពាណិជ្ជករ ឬអ្នកដឹកនាំក្រុមហ៊ុនត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីបីខែ (៣ខែ) ទៅមួយឆ្នាំ (១ឆ្នាំ) ។

**មាត្រា៥៤ថ្មី .-** ក្នុងរយះកាលដែលព្រះរាជាណាចក្រកម្ពុជានៅមិនទាន់មានតុលាការពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្មត្រូវរៀបចំថែរក្សាច្បាប់ចំលងនៃសៀវភៅបញ្ជីពាណិជ្ជកម្ម និង ច្បាប់ដើមនៃរាល់ឯកសារដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម ការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម រហូតដល់តុលាការពាណិជ្ជកម្មត្រូវបានបង្កើតឡើង ។

**មាត្រា៥៧ថ្មី .- (មាត្រា ៥៨ចាស់)**

រាល់ពាណិជ្ជករ និងរាល់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលបានធ្វើសកម្មភាពមុនការប្រកាសឲ្យប្រើច្បាប់នេះ ត្រូវប្តឹងសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជ

កម្ម ក្នុងរយៈពេលប្រាំមួយខែ(៦ខែ) ។ បើមានការចាំបាច់ក្រសួងពាណិជ្ជកម្មអាច សំរេចបន្តរយៈពេលនេះបានប្រាំមួយខែ (៦ខែ) ទៀត ។

**មាត្រា៥៨ថ្មី .-** **(មាត្រា ៥៩ចាស់)**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៥៩ថ្មី .-** **(មាត្រា ៦០ចាស់)**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

**ព្រះរាជក្រម នស/រកម/១១៩៩/១៣**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា